ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី
សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣

**លេខ និងឈ្មោះសំណុំរឿង : ៩៧/០៥ - ក្រុមហ៊ុន ហួ អ៊ី ហ្គាមិន**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥**

# សេចក្តីសម្រេចអាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

សមាសភាពក្រុមអាជ្ញាកណ្តាល

-អាជ្ញាកណ្តាលជ្រើសឡើងដោយភាគីនិយោជក : លោក **អ៊ុក រី**

-អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : លោក **អន ណន**

-ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : លោក **គុយ នាម**

ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ហួ អ៊ី ហ្គាមិន ( CHINAREA GARMENT , Cambodia )**

អាសយដ្ឋាន : ផ្លូវលំសង់ថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៨៨៣ ២១៩/០១២ ៨៧០ ៥០៥

តំណាងភាគីនិយោជក :

១ - អ្នកស្រី សុខ ហ៊ុង ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធ- សហជីពឯករាជ្យ និង ប្រជាធិបតេយ្យ

អាសយដ្ឋាន : គ្មាន

ទូរស័ព្ទ : ០១២ ២៨២ ៥៣១

តំណាងកម្មករនិយោជិត : អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីកម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនទទួលយក កញ្ញា ហោ លីតា ចូលធ្វើការវិញជាធម្មតា ដោយឡែកភាគីក្រុមហ៊ុនមិនឯកភាពទទួលយក កញ្ញា ហោ លីតា ចូលធ្វើការវិញទេ ដោយអះអាងថា កញ្ញាជាកម្មករសាកល្បង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី ១២ ផ្នែកទី ២ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ។ ប្រកាស លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១០១ កកបវ/វក. ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៩ ខែសីហាឆ្នាំ ២០០៥។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ "A" វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

បញ្ហានៃនីតិវិធី : គ្មាន

ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

២ ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក**

១-លក្ខន្តិកៈរបស់ក្រុមហ៊ុន ឆាយណារា ហ្គាមេន

២-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

៣-ពាក្យសុំចូលបំរើការងារ និងកិច្ចសន្យាការងារសាកល្បង របស់ឈ្មោះ ហោ លីតា ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៥

៤-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥

៥-បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥

៦-តារាងបើកប្រាក់ឈ្នួលខែកក្កដា របស់ឈ្មោះ ហោ លីតា

៧-លិខិតលាលែងពីការងាររបស់ ហោ លីតា ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៥

៨-លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥ របស់នាយកក្រុមហ៊ុនកាត់ដេរ ហួ អ៊ី ជូនអ្នកស្រី សុខ ហ៊ុង ដើម្បីចូលរួមសវនាការ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត**

១-សំណើសុំដកពាក្យបណ្តឹងរបស់សហជីពឯករាជ្យ និងប្រជាធិបតេយ្យ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-លិខិតលេខ ១១៨១ ក.ក.ប.វ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ របស់ឯកឧត្តម ញ៉ែប ប៊ុនជិន រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំដោះស្រាយវិវាទការងាររួមនៃសហគ្រាស យីហោក្រុមហ៊ុន ហួ អ៊ី ហ្គាមិន

២-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហួ អ៊ី លេខ ១០១ ក.ក.ប.វ/វក. ចុះ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៥ របស់លោក កុយ ទេពដារារុំ ប្រធាននាយកដ្ឋានវិវាទការងារ

៣-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ហួ អ៊ី ចូលរួមសវនាការ លេខ ២៧៤ លកអ. ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៥

២-លិខិតអញ្ជើញនាយកក្រុមហ៊ុន ហួ អ៊ី ចូលរួមសវនាការ លេខ ២៧៣ លកអ. ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ ។

អង្គហេតុ

ក្រុមហ៊ុន ហួ អ៊ី ហ្គាមិន មានទីតាំងនៅ ផ្លូវលំសង់ថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានជួលកម្មករសរុបប្រហែល ៦៥០ នាក់ ។ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងដោយផ្ទាល់មាត់ពីកម្មករនិយោជិត ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរលក្ខខណ្ឌការងារ ឱ្យបានត្រឹមត្រូវ ។ បន្ទាប់ពីទទួលព័ត៌មាននេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីចុះធ្វើការផ្សះផ្សាដល់ទីតាំងរោងចក្រ ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ០៤ ចំណុច លើការទាមទាររបស់កម្មករនិយោជិត ចំនួន ០៥ ចំណុច រីឯចំណុចមិនសះជា ១ ចំណុចត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥ ។ បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ភាគីទាំងអស់នៃវិវាទត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះហៅមកចូលរួមសវនាការ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ វេលាម៉ោង ១៤:០០ រសៀល នៅលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតមិនបានចូលរួមសវនាការទេ ដោយសារខ្លួនបានផ្ញើលិខិតសុំដកពាក្យបណ្តឹងរបស់ខ្លួនមកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៥ រួចហើយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចសេចក្តីដូចខាងក្រោម :

ហេតុផលនៃសេចក្តីសម្រេច

យោងតាមលិខិតរបស់សហព័ន្ធសហជីពឯករាជ្យ និងប្រជាធិបតេយ្យ និងសហជីពមូលដ្ឋាននៃក្រុមហ៊ុន ហួ អ៊ី ហ្គាមិន ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការសុំបញ្ចប់សុំណុំរឿង ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាមទារបានដកការទាមទាររបស់ខ្លួនវិញ ដូច្នេះរឿងនេះត្រូវបញ្ចប់ជាស្វ័យប្រវត្តិ ។

បង្គាប់

សំណុំរឿងលេខ ៤៧/០៩-ក្រុមហ៊ុន ហួ អ៊ី ត្រូវបិទជាស្ថាពរ ។

ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : អ៊ុក វី

ហត្ថលេខា:------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : អន ណាន

ហត្ថលេខា:------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : កុយ នាម

ហត្ថលេខា:------------------------------